**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
លេខ : ០០១ ដនស/សណន.

# សេចក្តីណែនាំ
# ស្តីពី
# ការលើកកម្ពស់សោភណភាពនិងបរិស្ថាន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព និងការរៀបចំប្រអប់សំបុត្រនៅតាម គម្រោងអភិវឌ្ឍដី គម្រោងសាងសង់ និងសំណង់

ដើម្បីអនុវត្តច្បាប់ស្តីពីសំណង់ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងគោលបំណងលើកកម្ពស់សោភណភាព បរិស្ថានល្អ និងសិទ្ធិរបស់ជនមានពិការភាព សម្រាប់ការរស់នៅប្រកបដោយចីរភាពនិងបរិយាបន្ន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំ លោក លោកស្រី ជាម្ចាស់គម្រោងអភិវឌ្ឍដី ម្ចាស់គម្រោងសាងសង់ ឬម្ចាស់សំណង់ ដូចតទៅ៖

**ទី១** ត្រូវរៀបចំសួនច្បារជ្រាបទឹកនិងដាំដើមឈើប្រណិត ជាអាទិ៍ ផ្ចង់ នាងនួន ក្រញូង និងរៀបចំសួនបៃតងមានដាំស្មៅនិងផ្កាដែលមានក្លិនក្រអូបនៅក្នុងគម្រោងអភិវឌ្ឍដី គម្រោងសាងសង់ ឬសំណង់ ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

**ទី២** ត្រូវរៀបចំឱ្យមានអាងសិបទិចនិង/ឬប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ឬអាងប្រព្រឹត្តកម្មសំណល់រាវ ដើម្បីសម្អាតទឹកកខ្វក់ឬសំណល់រាវ មុននឹងបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈឬតំបន់ទឹកសាធារណៈ ដោយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដាបញ្ចេញទឹកកខ្វក់ឬកម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវនៅគ្រប់គម្រោងអភិវឌ្ឍដី គម្រោងសាងសង់ ឬសំណង់ ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ២៣៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ អនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក និងអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក។

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

**ទី៣** ត្រូវរៀបចំឱ្យមានធុងសំរាមរួមសម្រាប់រក្សាទុកនូវកញ្ចប់សំរាមសំណល់រឹងដែលបានវេចខ្ចប់ដោយថង់ក្នុងទីតាំងឬបរិវេណគ្រប់គ្រងរបស់ខ្លួន និងធុងរក្សាទុកសំរាមសំណល់រឹងនៅតាមចំណែកឯកជននីមួយៗ និងច្រកយកសំរាមចេញ ព្រមទាំងគ្រប់គ្រងអនាម័យសមស្របតាមបទដ្ឋានបច្ចេកទេសនៅគ្រប់គម្រោងអភិវឌ្ឍដី គម្រោងសាងសង់ ឬសំណង់ ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**ទី៤** ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពគ្រប់ប្រភេទអាចចល័តទី ចេញ-ចូល ឡើង-ចុះ និងប្រើប្រាស់ដោយងាយស្រួល ប្រកបដោយសុវត្ថិភាព និងគ្មានឧបសគ្គ ជាអាទិ៍ ចំណតរថយន្ត ច្រកផ្លូវ ផ្លូវជម្រាល បង្កាន់ដៃសុវត្ថិភាព ទ្វារនិងដៃទ្វារ ជណ្តើរយោងនិងទ្វារប៊ូតុងបញ្ជាជណ្តើរយោង ឧបករណ៍ប្រាប់ដំណឹងជាសូរសម្លេង ស្លាកសញ្ញា ភ្លើងសញ្ញា បញ្ជរផ្តល់សេវា បន្ទប់ទឹក និងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗនៅតាមគម្រោងសាងសង់ ឬសំណង់ស្របតាមបទដ្ឋានបច្ចេកទេសដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសអន្តរក្រសួង លេខ២៤៨ សអយ/ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

**ទី៥** ត្រូវរៀបចំឱ្យមានទីតាំងប្រអប់សំបុត្ររួមសម្រាប់គម្រោងអគារពហុមុខងារ អគារប្រើប្រាស់ចម្រុះ អគារពាណិជ្ជកម្ម អគារសហកម្មសិទ្ធិ និងរៀបចំប្រអប់សំបុត្រតាមលំនៅឋានឯកជនតាមបទដ្ឋានបច្ចេកទេសកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ទទួលបានសេចក្តីណែនាំនេះ លោក លោកស្រី ជាម្ចាស់គម្រោងអភិវឌ្ឍដី ម្ចាស់គម្រោងសាងសង់ ឬម្ចាស់សំណង់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ កាលប្បវត្តិ